# មេរៀនទី៣៖ ព្រះអង្គសង្គ្រោះយាងមកដល់ហើយ

លូកា ១៖២៦- ២៖៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/FN1AK43SpzY

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/UT6MKZ1_Yj8

**គោលបំណង៖** ព្រះអង្គយាងមកដើម្បីជួយសង្គ្រោះរាស្ត្រទ្រង់អោយរួចពីបាប

**ខគម្ពីរចងចាំ៖** ម៉ាថាយ១៖២១ *"នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប"។*

**ចំរៀង** ( *យូធូបលីង* )៖

១. អំណរដល់លោក https://youtu.be/Au-7Uxb65Ng

២. Joy To the World Everybody https://youtu.be/edNUvBxfgnE

៣. ទារកតូចអើយ https://youtu.be/l985NM7o_z0

៤. ណូអែលឆ្នាំនេះ https://youtu.be/A59-uQCZfxE

## ១. អធិស្ឋាន

អរគុណព្រះអង្គសំរាប់ថ្ងៃដ៏អស្ចារ្យ ដែលទ្រង់បានប្រទានពរមកកូននៅក្នុងពេលនេះ គឺជាកាដូរដ៏ធំ បំផុតដែលព្រះអង្គយាងមកផែនដីនេះ ដើម្បីមកជួយសង្គ្រោះកូន។ កូនសូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ស្វែងរកក្រោលសត្វ និងបុត្រតូច»

សំភារៈដែលត្រូវការ៖ ក្រដាស ឬ កាត ៤សន្លឹក ដោយសរសេរជាពាក្យឬដាក់ជារូបភាពក៏បាន (បើមានរូបភាព) តែបើមិនមានគ្រូត្រូវសរសេរនៅលើក្រដាសនោះដូចជា៖ ក្រដាសទី១ សរសេរពាក្យថា ផ្ទះ ក្រដាសទី២ ក្រោលសត្វ ក្រដាសទី៣ បុត្រតូច ក្រដាសទី៤ ក្រោលសត្វ និងបុត្រតូច។

ក. មុនចាប់ផ្តើមថ្នាក់រៀន គ្រូយកក្រដាស/កាតទាំង ៤ សន្លឹកនោះទៅបិទនៅលើជញ្ជាំងនៅតាមជ្រុងទាំង ៤ ផ្សេងៗគ្នា ដោយបិតផ្កាប់មុខទៅជញ្ជាំង (កុំឲ្យសិស្សមើលឃើញ)។

ខ.ឲ្យកុមារទាំងអស់ឈរនៅចំកណ្តាល ដោយគ្រូត្រូវចាក់ភ្លេងឲ្យកុមាររាំជុំវិញទីធ្លានោះឬក៏ ច្រៀងតាមបទ ភ្លេង រហូតនៅពេលភ្លេងឈប់កុមារត្រូវរត់ទៅកន្លែងណាដែលមានបិតកាត/ក្រដាស។

គ. បន្ទាប់មកគេត្រូវបើកកាតតាមកន្លែងដែលពួកគេបានរត់ទៅ។ បើកាតណាមានរូបភាព ឬពាក្យក្រោលសត្វ និង បុត្រតូច ក្រុមនោះជាអ្នកឈ្នះ។

## ៤.ការណែនាំមេរៀន

ប្រសិនបើនៅថ្ងៃនេះនាយករដ្ឋមន្រ្តីចុះមកភូមិរបស់ប្អូនតើប្អូនត្រូវរៀបចំអ្វីខ្លះដើម្បីទទួលគាត់? យើងត្រូវរៀបចំ កៅអី តុ កំរាលព្រំ មានអ្នកស្វាគមន៍ ហើយនិងមានអ្នកការពារ ឆ្វេងស្តាំ។ តើប្អូនមានអារម្មណ៍ដូចម្តេចនៅពេលដែលមាននាយករដ្ឋមន្រ្តីមកលេងភូមិរបស់ប្អូន? តើប្អូននឹងមានអារម្មណ៍រំភើប? ខ្លាច? ឬក៏រីករាយ? ព្រះអង្គបានយាងមក ដើម្បីជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ ដូចដែលទ្រង់បានសន្យាតាំង

ពីដើមដំបូងមកម្លេះ។ ពេលដែលព្រះមេស្ស៊ីយាងមកភ្នំទាំងឡាយនឹងឱនចុះ។ សមុទ្រនឹងក្រើកឡើង។ ដើមឈើទាំងឡាយនឹងទះដៃអបអរសាទរទ្រង់។ ប៉ុន្តែផែនដីនិងទប់ដង្ហើមដោយស្ងប់ស្ងាត់។ តើប្អូននិងរៀបចំបែបណាសំរាប់ទទួលការយាងមករបស់ព្រះយេស៊ូវ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានស្រីក្រមុំម្នាក់ឈ្មោះម៉ារាបានភ្ជាប់ពាក្យជាមួយ នឹងបុរសម្នាក់ឈ្មោះយ៉ូសែប (យ៉ូសែបជាកូនចៅជំជាន់ក្រោយៗរបស់ស្តេចដាវីឌ)។ នៅព្រឹកមួយស្រីក្រមុំម្នាក់នោះកំពុងធ្វើការដូចសព្វដង ស្រាប់តែមានទេវតាពេញដោយពន្លឺចេញមកជួបនាង ទេវតានោះមានព្រះនាមថា កាព្រីយ៉ែល ជាអ្នកនាំសារពិសេសមកពី ស្ថានសួគ៌បានឈរនៅចំពោះនាង(**លូកា ១៖៣០-៣២** តែទេវតានិយាយថា កុំខ្លាចអី ម៉ារាអើយ ដ្បិតព្រះបានប្រោសមេត្តាដល់នាងហើយ មើលនាងនឹងមានគភ៌ប្រសូតបានបុត្រា១ ដែលនាង ត្រូវថ្វាយព្រះនាមថា «**យេស៊ូវ**» បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ថា ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត ) ទេវតា កាព្រីយ៉ែល បាននិយាយពីការយាងមករបស់ព្រះអង្គសង្គ្រោះ គឺព្រះមេស្ស៊ី!

(**លូកា ១៖៣៤-៣៥** តែម៉ារាសួរទេវតាថា ខ្ញុំមិនស្គាល់ប្រុសណាផងដូច្នេះ តើធ្វើដូចម្តេច នឹងឲ្យ ការនេះសំរេចបាន ទេវតាក៏ឆ្លើយថា ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិត លើនាង ហើយ ព្រះចេស្តានៃព្រះដ៏ខ្ពស់បំផុត នឹងមកគ្របបាំងនាងដោយស្រមោល ហេតុដូច្នេះ បុត្របរិសុទ្ធដែល នឹងប្រសូតមកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ )។ នាងក៏និយាយថា សូមឲ្យបានសំរេចដូច ពាក្យលោកចុះ។ ពិតប្រាកដណាស់ ដូចជាពាក្យទេវតាបានប្រាប់មែន ក្រោយនោះមកនាងម៉ារាជិតគ្រប់ ខែសំរាលកូនហើយឥឡូវនេះនាងម៉ារានិង យ៉ូសែបកំពុងធ្វើដំណើរទៅបេថ្លេហិមជាស្រុកកំណើតរបស់ ស្តេចដាវីឌ។ នៅពេលដែលទៅដល់បេថ្លេហិមនាងក៏ចាប់ផ្តើមឈឺពោះ ហើយគ្រប់បន្ទប់នៃផ្ទះសំណាក់ ពេញទាំងអស់ក៏គ្មានកន្លែងណាដែលទំនេរសោះ។

ម្ចាស់ផ្ទះសំណាក់បានប្រាប់ម៉ារា និងយ៉ូសែបឲ្យទៅរកកន្លែងស្នាក់នៅផ្សេងទៀត តើឲ្យពួកយើងទៅស្នាក់នៅកន្លែងណា?នៅតែបន្តិចទៀតម៉ារានឹងសំរាលកូនហើយ។ ពួកគេមិនអាចរកកន្លែងស្នាក់នៅបានសោះលើកលែងតែក្រោលសត្វមួយដែលទ្រុឌទ្រោមទៅហើយ ដូច្នេះពួកគេក៏បានសំរាលបុត្រតូចនៅកន្លែងនោះ ព្រះមេស្ស៊ីជាព្រះអង្គសង្គ្រោះនៃពិភពលោកបានប្រសូត្រ នៅក្នុងក្រោលសត្វជាកន្លែងដែលហ្វូងគោ ហ្វូងលា ហើយហ្វូងសេះកំពុងនៅ។ នៅក្នុងក្រោលសត្វនាយប់ដ៏សែនស្ងាត់ជ្រងំ នាងម៉ារានិងយ៉ូសែបបានរុំទារកតូចនឹងសំពត់ ដើម្បីជួយអោយកក់ក្តៅដោយប្រើស្នូកដាក់ចំណីសត្វធ្វើជាគ្រែ ឲ្យបុត្រតូចផ្ទំនៅក្នុងស្នូកនោះ។ ម៉ារានិងយ៉ូសែបបានដាក់ឈ្មោះទ្រង់ដូចជាទេវតាបានប្រាប់ (ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប) ព្រោះនេះគឺជាការពិតណាស់ដ្បិតទ្រង់បានយាងមកពិតមែន។ រឿងនេះបានសំរេចដូចជាសេចក្តីទំនាយបានទាយទុកនិងតាមការសន្យារបស់ព្រះ ដែលទ្រង់បានចាត់ព្រះយេស៊ូវមករកយើង!

## ៦. សំនួរពិភាក្សា

១. តើទេវតាបានជួបនរណា? *(ម៉ារា)*
២. តើទេវតាដែលម៉ារាបានជួបនោះមានឈ្មោះអ្វី? *(កាព្រីយ៉ែល)*
៣. តើបុត្រតូចបានប្រសូតនៅកន្លែងណា? *(ក្រោលសត្វ)*
៤. តើបុត្រតូចនោះមានព្រះនាមអ្វី? *(យេស៊ូវ)*
៥. តើបុត្រតូចនោះយាងមកផែនដីដើម្បីអ្វី ?*(ជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប)*
៦. តើប្អូនៗគិតថាព្រះយេស៊ូវយាងមកសង្គ្រោះមនុស្សប្រភេទណាខ្លះ? *(មនុស្សគ្រប់គ្នា)*

### ៧. ល្បែងកំសាន្ត «បកសំបក»

សម្ភារៈដែលត្រូវការ៖ ក្រដាស A4 ចំនួន ១៥ សន្លឹក

ក. គ្រូត្រូវសរសេរពាក្យដាក់នៅក្នុងក្រដាសនោះជាពាក្យផ្សេងៗគ្នាដូចជា សើច យំ រាំ ច្រៀង ធ្វើកាយវិកា សត្វស្វា សំលេងសត្វទា ដើរបង្ហាញម៉ូត។ល។ ក្នុងចំណោមក្រដាសទាំងនោះត្រូវមានរង្វាន់២ ឬ៣ សន្លឹក។

ខ. បន្ទាប់មកគ្រូយកក្រដាសដែលសរសេររួចមក ផ្ទួលចូលគ្នាឲ្យក្លាយជាបាល់ ដែលយើងអាចបកបានជា ស្រទាប់ៗ។

- ឲ្យកុមារអង្គុយជុំវិញជារង្វង់មូល
- ហើយឲ្យបាល់នោះទៅកុមារណាម្នាក់
- ទន្ទឹមនឹងបទភ្លេងដែលគ្រូចាក់ឲ្យកុមារហុចបាល់នោះតៗគ្នា
- នៅពេលបទភ្លេងឈប់ហើយ បាល់នៅលើអ្នកណាអ្នកនោះត្រូវបកបាល់មួយស្រទាប់ បើបើកត្រូវចំពាក្យ អ្វី កុមារត្រូវធ្វើគ្រាប់តាមពាក្យនៅក្នុងក្រដាសនោះ។
- យើងបន្តលេងល្បែងនេះរហូតដល់បកស្រទាប់ក្រដាសនោះអស់។

### ៨. ខគម្ពីរចងចាំ

**ម៉ាថាយ១៖២១** “នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប” ។

### ៩. ហត្ថកម្ម



**ជំរើសទី១៖**បង្រៀនឲ្យកុមារចេះធ្វើក្រោលសត្វ(ដាក់បុត្រតូច និងឈ្មោះអេម៉ាញូអែល)ក្រោលសត្វនេះធ្វើ ពីឈើការ៉េមដាក់ដំបូល។

**ជំរើសទី១៖** ផាត់ពណ៌សូមថតចំលងរូបភាពឲ្យកុមារផាត់ពណ៌។

### ១០. ចំរៀង

*(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

អរគុណព្រះអង្គសំរាប់កាដូរពិសេសនៅក្នុងថ្ងៃមួយនេះ ព្រះអង្គបានយាងមកដោយផ្ទាល់ ដើម្បីជួយសង្គ្រោះកូនៗ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះអង្គបានយាងមកដោយផ្ទាល់មិនមកដើម្បីដាក់ទោសដល់រាស្ត្រទ្រង់ទេ ប៉ុន្តែមកដើម្បីជួយសង្គ្រោះដល់រាស្ត្ររបស់ទ្រង់វិញ ដោយព្រះបានបង្រៀន ប្រោសជំងឺ ប្រដៅជំរង់និងធ្វើការអស្ចារ្យជាច្រើន។ តាមរយៈព្រះ យេស៊ូវ ដែលជាព្រះមេស្ស៊ី ព្រះអង្គបានត្រៀមជាស្រេចដើម្បីជូតទឹកភ្នែកពួកគេចេញ។ មនុស្សគ្រប់គ្នាត្រូវការសេចក្តីសង្គ្រោះពីព្រោះមនុស្សគ្រប់គ្នាសុទ្ធតែមានបាបមិនថាកុមារឬ មនុស្សចាស់ទេ។ សូមអធិស្ឋាន សំរាប់កុមារទាំងអស់ ដែលអ្នកកំពុងបង្រៀននៅថ្ងៃនេះ ដូច្នេះហើយពួកគេអាចនឹងមកស្គាល់ព្រះមេស្ស៊ីដែរ។

